# ពន្លាជាតិកម្ពុជា

- ឈ្មោះពន្លាជាតិ៖ ជីវិតដ៏រុងរឿង
- ប្រធានបទ៖ "ការសង្គ្រោះជីវិត" ដោយផ្តោតលើសន្តិសុខស្បៀង ការអភិវឌ្ឍប្រកបដោយចីរភាព សុខភាពសាធារណៈ សន្តិសុខទឹក ភាពធន់ និងការអភិរក្សវប្បធម៌។
- ពន្លាកម្ពុជា៖ កម្ពុជា បង្ហាញពីការប្រេបាច់បញ្ចូលគ្នា វប្បធម៌បុរាណ-សម័យឱ្យក្លាយជាស្ពលនៃទស្សនទានរបស់ពិព័រណ៍ពិភពលោក ធ្វើឱ្យពិភពលោកដឹងថា កម្ពុជានៅតែអភិរក្សមរតកវប្បធម៌របស់ខ្លួនបានគង់វង្សឋិតបេរពីបុរាណ-សម័យបច្ចុប្បន្ន-អនាគតទៅមុខ។



ទីតាំងពន្លាជាតិកម្ពុជា៖
BS3 ស្ថិតក្នុងតំបន់
ប្រធានបទ
ការសង្គ្រោះជីវិត







## ព្រឹត្តិការណ៍ និងកម្មវិធី

**ទិវាជាតិកម្ពុជា៖** នឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៥ ដោយមានព្រឹត្តិការណ៍អម ផ្សេងៗព្រមទាំងមានសម្តែងសិល្បៈផងដែរ។

**កម្មវិធីក្នុងពន្លាជាតិ៖**
- ការផ្តល់អាជីវកម្ម
- ការសម្តែងសិល្បៈ
- ការផ្សព្វផ្សាយផលិតផលខ្មែរ

**តំបន់ពាណិជ្ជកម្ម៖**
- ហាងលក់វត្ថុអនុស្សាវរីយ៍ធ្វើដោយដៃ
- ផលិតផលខ្មែរ





## Towards a brighter future for all

# EXPO 2025

### OSAKA, KANSAI, JAPAN



## ប្រធានបទ: ការរៀបចំសង្គមសម្រាប់អនាគតជីវិតរស់នៅ

ពិព័រណ៍ពិភពលោកអូសាកា ២០២៥ កាន់សៃ ជប៉ុន នឹងក្លាយជាឱកាសមួយសម្រាប់ពិភពលោកក្នុងការជួបជុំគ្នានៅកន្លែងតែមួយ ក្រោមប្រធានបទ "ជីវិត" យើងសង្ឃឹមថាពិព័រណ៍នេះនឹងជំរុញការផ្លាស់ប្តូរតម្លៃចម្រុះពីជុំវិញពិភពលោក លើកទឹកចិត្តឱ្យមានការតភ្ជាប់ និងការបង្កើតថ្មីៗ ជម្នះឧបសគ្គជាសាកល ការពារជីវិត និងតាមរយៈការឆ្លុះបញ្ចាំងពីខ្លឹមសារនៃជីវិត និងរបៀបដែលយើងរស់នៅ។ យើងសង្ឃឹមថានឹងធ្វើឱ្យវាក្លាយជាពិព័រណ៍ដែលបង្ហាញពីចក្ខុវិស័យនៃក្តីសង្ឃឹមសម្រាប់អនាគត

រយៈពេល៖
**ថ្ងៃអាទិត្យ ទី១៣ ខែមេសា ដល់ថ្ងៃចន្ទ ទី១៣ ខែតុលា ឆ្នាំ២០២៥**

ទីកន្លែង៖
**Yumeshima Island, Osaka**

បើកពីម៉ោង៖
**៩:០០ ដល់ ២២:០០**







Expo 2025 Osaka, Kansai, Japan

**Official Website**

Expo 2025

Purchasing Ticket

Pavilions

Group Ticket

Event Calendar

This pamphlet was made by the participants of the Training Program on International Events for ASEAN Countries organized by Ministry of Economy, Trade and Industry (METI) with the support of Japan Association for the 2025 World Exposition and Japan National Tourism Organization (JNTO).



Explore the Theme of the Expo on your trip!

# ស្វែងរកកន្លែងអស្ចារ្យរបស់ជប៉ុន សម្រាប់ផ្តិតរូបភាព

Theme of Expo 2025 Osaka, Kansai

Designing Future Society for Our Lives

Subthemes (Trip theme)

Saving Lives | Empowering Lives | Connecting Lives

## Epic views, thrilling activities ahead — KYOTO



### AMANO HASHIDATE

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 2.5h
រថយន្ត 2h~ (140km)

អ្នកទទួលបាននូវបរិយាកាសថ្មីល្អជាទីគាប់ចិត្ត ជាមួយការជិះទោងខ្សែកាបចំហ ឡើងទៅកំពូលភ្នំ ដោយ-មើលឃើញនូវទិដ្ឋភាពស្រស់ស្អាតនៃទីក្រុងពីលើកំពូលភ្នំ និងគយគន់ធម្មជាតិស្រស់បំព្រងអមសងខាងផ្លូវ។ នៅលើកំពូលភ្នំមានសកម្មភាពជាច្រើន ដូចជាធាក់កង់លើអាកាស សួនកម្សាន្តមនុស្សគ្រប់វ័យផងដែរ។

## Insta-Worthy Onsen Moments Await — HYOGO



**Kinosaki Onsen** គឺជារមណីយដ្ឋានទឹកក្តៅប្រវត្តិសាស្ត្រនៅភាគខាងជើងខេត្ត Hyogo ។

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 2.5h
រថយន្ត 3h~ (165km)

អ្នកនឹងទទួលបានអារម្មណ៍ថ្មីដែលសណ្ឋាគារនៅទីនោះរៀបចំជាមួយនឹងរចនាបថផ្ទះបែបជប៉ុន ដែលគួរឱ្យចាប់អារម្មណ៍ ទាំងការផ្តល់សំលៀកបំពាក់បែបជប៉ុនឈុតយូកាតាស(Yukata) អ្នកនឹងឃើញភ្ញៀវទេសចរស្លៀកពាក់ឈុតនេះ ដើរជុំវិញទីក្រុង Onsen និងសូមកុំភ្លេចញ៉ាំអាហារប្រចាំតំបន់ ជាពិសេសក្តាមដែលល្បីក្នុងតំបន់នេះផងដែរ។

## វាលខ្សាច់ Tottori និង សារមន្ទីរខ្សាច់ — TOTTORI

### Sand Museum



Tottori មានវាលខ្សាច់លាតសន្ធឹងលើឆ្នេរសមុទ្រប្រហែល ១៦ គីឡូម៉ែត្រតាមបណ្តោយសមុទ្រជប៉ុន។ អ្នកនឹងទទួលនូវបទពិសោធន៍ក្នុងការដើរលើវាលខ្សាច់ដ៏ល្វឹងល្វើយ ជិះអូដ្ឋកម្សាន្ត ដូចនៅតំបន់អារ៉ាប់ ផងដែរ។



មិនឆ្ងាយពីវាលខ្សាច់មានសារមន្ទីរតែមួយគត់ដែលបង្ហាញរូបចម្លាក់ខ្សាច់ដ៏ធំដោយវិចិត្រករមកពីជុំវិញពិភពលោក។ ការតាំងពិព័រណ៍នេះផ្លាស់ប្តូរជារៀងរាល់ឆ្នាំ និងមានរយៈពេលពីពាក់កណ្តាលខែមេសាដល់ដើមខែមករានៃឆ្នាំបន្ទាប់។ រាល់ការតាំងពិព័រណ៍មានប្រធានបទទៅតាមប្រទេស ឬតំបន់។

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 3.5h
រថយន្ត 3h~ (195km)

## ដីកន្លែងប្រវត្តិសាស្ត្ររបស់ Samurai — SHIGA



**Hikone Castle៖** ប្រាសាទ Hikone គឺជាប្រាសាទមួយក្នុងចំណោមប្រាសាទចំនួន ១២ របស់ប្រទេសជប៉ុន(ប៉មប្រាសាទ) ដែលរក្សាទម្រង់ដើម។

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 1.5h
រថយន្ត 2h~ (125km)



ការឡើងទៅប៉មតួប្រាសាទមានច្រកចូលតូចចង្អៀត និងចោតខ្លាំង ព្រោះប្រាសាទនេះសាងសង់ជាប៉ម/បន្ទាយដើម្បីត្រួតពិនិត្យ និងយាមក្រុងពីសត្រូវនាសម័យកាលនោះ។ ពេលអ្នកឡើងដល់កំពូលប៉មប្រាសាទនឹងទទួលបាននូវទិដ្ឋភាពដ៏ស្រស់ស្អាតនៃបរិវេណប្រាសាទ ទីក្រុង Hikone និងបឹង Biwa។ សូមកុំភ្លេចភ្លក្ស សាច់គោ Omi ដែលល្បីប្រចាំតំបន់នេះផងដែរ។

## ជិះទូកលេង Ine Bay — KYOTO



ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 4h
រថយន្ត 2.5h~ (165km)

Ine គឺជាទីក្រុងមួយដែលមានទីតាំងនៅជុំវិញឈូងសមុទ្រ Ine នៅភាគខាងជើងខេត្ត Kyoto។ ទីក្រុងនេះមានប្រវត្តិដ៏យូរលង់ ជាភូមិនេសាទ ហើយត្រូវបានចាត់ទុកថាជាភូមិដ៏ស្រស់ស្អាតបំផុតមួយនៅក្នុងប្រទេសជប៉ុន។ ជាពិសេសការជិះទូកទស្សនាទិដ្ឋភាពដ៏ស្រស់បំព្រងនៃភូមិសាស្ត្រនេះ អមជាមួយការឱ្យចំណីដល់សត្វរំពៃ និងឥន្ទ្រី ជាច្រើនហោះហើរតាមប្រដេញនឹងទូកទេសចរណ៍ និងចឹកចំណីដែលអ្នកទេសចរផ្តល់ឱ្យវាពិតជារំភើប និងរីករាយក្រៃលែង។

## Hiroshima — HIROSHIMA



ក្រៅពីនោះកោះ Miyajima "កោះទីសក្ការៈនិងមានក្លោងទ្វារ Torii ដ៏ធំ" មានចម្ងាយមិនឆ្ងាយពីទីក្រុងប៉ុន្មានទេ ជាកន្លែងទេសចរណ៍ដ៏ល្បីល្បាញដែលអ្នកទេសចរទាំងអស់មិនដែលត្រូវរំលង និងមានសត្វក្តាន់ដើរពាសពេញលើកោះនេះផងដែរ។

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 2h
រថយន្ត 4.5h~ (331km)

Hiroshima ជាទីក្រុងទំនើបមួយនៅលើកោះ Honshu របស់ប្រទេសជប៉ុន ត្រូវបានបំផ្លាញដោយគ្រាប់បែកបរមាណូក្នុងអំឡុងសង្គ្រាមលោកលើកទីពីរក្នុងឆ្នាំ១៩៤៥។ បន្ទាប់ពីសង្គ្រាម ការខិតខំប្រឹងប្រែងយ៉ាងខ្លាំងត្រូវបានកសាងទីក្រុងនេះឡើងវិញ និងបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌវប្បធម៌ពិភពលោកមានវិមានគ្រាប់បែកបរមាណូ(A-bomb Dome) និងសួនឧទ្យានអនុស្សាវរីយ៍សន្តិភាពហ៊ីរ៉ូស៊ីម៉ា(Hiroshima Peace Memorial)។

## La Collina Ōmi-Hachiman — SHIGA



### La Collina Omi-Hachiman

ចាប់ផ្តើមពីចំនុច៖ OSAKA
រថភ្លើង 1.5h
រថយន្ត 1.5h~ (100km)

La Collina Shiga

ជាកន្លែងទេសចរណ៍ដ៏ល្បីមួយក្នុងតំបន់កាន់សៃ ខាងផ្នែកធ្វើនំនិងបង្អែមជប៉ុន និងបស្ចិមប្រទេស ដោយរួមបញ្ចូលហាងល្បីរបស់ Taneya Club និង Harie ព្រមទាំងហាងកាហ្វេ និងហាងធ្វើនំប៉័ងcastella ជាពិសេសសម្បូរទៅដោយកន្លែងថតរូបដ៏ទាក់ទាញ។ សូមកុំភ្លេចភ្លក្សនំ Baumkuchen ដែលរស់ជាតិមិនអាចបំភ្លេចបាន។

## សារមន្ទីររំលឹកគ្រោះរញ្ជួយដី និងគ្រោះមហន្តរាយនុយក្លេអ៊ែ — FUKUSHIMA



ចាប់ផ្តើមពីចំនុច៖ OSAKA
1hr 5mins (ព្រលាន Itami)
1.5hr ពីព្រលាន Fukushima
រថភ្លើង 6.5h
រថយន្ត 10h~ (757km)

Fukushima ជានិមិត្តរូបនៃការប្រឈមនឹងឧបសគ្គ និងការកសាងឡើងវិញ បន្ទាប់ពីគ្រោះមហន្តរាយឆ្នាំ២០១១ កន្លងទៅ។ កន្លែងនេះបានក្លាយជានិមិត្តរូបនៃក្តីសង្ឃឹម ដោយរួមបញ្ចូលគ្នានូវភាពស្រស់ស្អាតនៃធម្មជាតិ និងការច្នៃប្រឌិត។ ***សារមន្ទីររំលឹកគ្រោះរញ្ជួយដី និងគ្រោះមហន្តរាយនុយក្លេអ៊ែរ*** ជាបេះដូងនៃតំបន់នេះ ដែលរក្សាទុកអនុស្សាវរីយ៍នៃថ្ងៃនោះ បង្ហាញរឿងរ៉ាវដ៏មានអត្ថន័យ និងមេរៀនដ៏សំខាន់មួយក្នុងជីវិតរស់នៅ។

